01047253

E328

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 12 / 2014
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Claudia FENZ**
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

## ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភស្តុតាង

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GUIRAUD

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២-១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ អនុលោមតាម សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលអង្គបុរេជំនុំជម្រះបានចេញនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[1]។

**បានឃើញ** ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ និង ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤[2]។

**ដោយរម្លឹកឡើងវិញ** ថាការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីពីសំណាក់មេធាវីការពារក្តី ខៀវ សំផន[3] បានបង្ខំឲ្យអង្គជំនុំជម្រះផ្អាកកិច្ចដំណើរនីតិវិធីរហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥[4]។

**បានឃើញ** សេចក្តីថ្លែងរបស់សហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន ដែលថា មេធាវីការពារក្តីនឹងរៀបចំខ្លួនរួចជាស្រេចដើម្បីចូលរួមក្នុងសំណុំរឿង០០២/០២ ក្រោយពីដាក់សារណាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១[5]។

**បានឃើញ** ថ្ងៃកំណត់នៃការដាក់សារណាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[6]។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/14 និងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តធិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/5/9។

[2] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E316។ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភ័ស្តុតាង ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ E322។

[3] សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ E321/2 កថាខណ្ឌ ១៣។ សម្រាប់ប្រវត្តិនីតិវិធីពេញលេញ សូមមើល សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ E321/2 កថាខណ្ឌ ១-១២។

[4] ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៣-៤ (ភាសាអង់គ្លេស)។

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២៤-២៥ (ភាសាអង់គ្លេស)។

**បានឃើញ** សំណើរួមរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យអង្គជំនុំជម្រះកំណត់ចំនួនថ្ងៃធ្វើសវនាការត្រឹម ៤ថ្ងៃ ក្នុងមួយសប្តាហ៍ ចាប់ពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ តទៅ[7]។

**ដោយរម្លឹកឡើងវិញអំពី** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកន្លងមកដែលថា ភាគីនឹង ទទួលបានផលប្រយោជន៍ពីការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការមកត្រឹម ៣ ថ្ងៃក្នុង ១ សប្តាហ៍ ខណៈ ពេលដែលភាគីកំពុងរៀបចំសារណាលើបណ្តឹងសាទុក្ខ យ៉ាងហោចណាស់រហូតដល់ដំណាច់ខែ ធ្នូ ឆ្នាំ ២០១៤[8]។

**ដោយរម្លឹកឡើងវិញអំពី** សេចក្តីសម្រេចបន្ទាប់មកទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកាត់ បន្ថយបន្ថែមទៀតនូវចំនួនថ្ងៃធ្វើសវនាការមកត្រឹម ២ ថ្ងៃក្នុង ១ សប្តាហ៍ រហូតដល់ថ្ងៃកំណត់ដាក់សារ ណាលើបណ្តឹងសាទុក្ខក្នុងខែ ធ្នូ ឆ្នាំ ២០១៤ ក្នុងគោលបំណងធ្វើឱ្យមានតុល្យភាពរវាងតម្រូវការ ចាំបាច់ដែលលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន ជាមួយនឹងសិទ្ធិរបស់ភាគីដទៃទៀតក្នុងការ ទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស[9]។

**យល់ឃើញថា** ការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការមកត្រឹម ២ ថ្ងៃក្នុង ១ សប្តាហ៍ នឹងលែងមានយុត្តិ កម្មទៀតហើយក្រោយពីការដាក់សារណាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។

---

6 សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប (អ.ជ.ត.ក) ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ F9។

7 សំណើរួមរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការកំណត់កាល បរិច្ឆេទសវនាការនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ E322/1។

8 ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E316 ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

9 ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភ័ស្តុតាង ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ E322 ទំព័រ ៣-៤។ អនុស្សរណៈ: “សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤” ចុះ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ E320/1 កថាខណ្ឌ ៦។

**យល់ឃើញថា** ដោយហេតុថាជនជាប់ចោទនីមួយៗមានវ័យចំណាស់ទៅហើយ ការវាយតម្លៃជាថ្មីលើសម្បទារបស់ពួកគាត់ នឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះប៉ាន់ប្រមាណសាជាថ្មីទៅលើកាលបរិច្ឆេទធ្វើសវនាការ ដោយផ្អែកលើព័ត៌មានចុងក្រោយបំផុត[10]។

**ដោយយល់ឃើញថា** មានភាពសមស្របក្នុងការរក្សានូវការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការ ៣ ថ្ងៃ ក្នុង ១ សប្តាហ៍ រហូតដល់អង្គជំនុំជម្រះមានលទ្ធភាពពិចារណាលើការវាយតម្លៃសម្បទាជាថ្មី។

**ដោយរម្លឹកឡើងវិញ** អំពីសេចក្តីសម្រេចពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្តីសម្រេចរបស់ខ្លួនក្នុងការផ្តល់អាទិភាពដល់សវនាការដេញដោលលើភ័ស្តុតាង ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[11]។

## ហេតុដូច្នេះ

**កំណត់កាលបរិច្ឆេទ** ចាប់ផ្តើមសវនាការដេញដោលលើភ័ស្តុតាងវគ្គដំបូងក្នុងសំណុំរឿង ០០២/០២ ចាប់ពីថ្ងៃ ព្រហស្បតិ៍ ទី ០៨ ខែ មករា ឆ្នាំ ២០១៥ តទៅ។

**ប្រកាសថា** លើកលែងតែមានការប្រកាសផ្សេងពីនេះ អង្គជំនុំជម្រះនឹងដំណើរការសវនាការចំនួន ៣ ថ្ងៃក្នុង ១ សប្តាហ៍ រហូតដល់ការវាយតម្លៃលើសម្បទាជាថ្មីមួយទៅលើជនជាប់ចោទបានចប់សព្វគ្រប់ ដោយចាប់ផ្តើមសវនាការពីម៉ោង ៩:០០ នាទី ពេលព្រឹក និងបញ្ចប់នៅម៉ោង ៤:០០ នាទី ពេលរសៀល។ សវនាការនឹងផ្អាកសម្រាប់ការទទួលទានអាហារថ្ងៃត្រង់ពីម៉ោង ១២:០០ ព្រឹក រហូតដល់ម៉ោង ១:៣០ រសៀល និងមានការសម្រាកម្តងនៅពេលព្រឹក និងម្តងទៀតនៅពេលរសៀល តាមការណែនាំរបស់ប្រធានអង្គជំនុំជម្រះ។

**កត់សម្គាល់ថា** ភាគីនានាត្រូវបានជូនដំណឹងតាមរយៈសារអេឡិចត្រូនិក អំពីលំដាប់លំដោយនៃសាក្សីអ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មសម្រាប់ប្រធានបទទី១ (ឧបសម្ព័ន្ធ I) ។

---

[10] សូមមើល ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E316 ទំព័រ ៣-៤។ *សូមមើលផងដែរ* ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការដែលនឹងចេញនៅពេលខាងមុខ។

[11] សេចក្តីសម្រេចស្តីពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E315។

**ភ្ជាប់ជាមួយដីកានេះ** នូវកាលបរិច្ឆេទសវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ សម្រាប់ដើមឆ្នាំ ២០១៥ (ឧបសម្ព័ន្ធ II)។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

**និល ណុន**